# វាជាសិទ្ធិរបស់អ្នកក្នុងការបោះឆ្នោត ៖ ការពារសម្លេងរបស់អ្នក ៖ ស្គាល់ពីសិទ្ធិរបស់អ្នក

តើអ្នកមានអាយុយ៉ាងតិច១៨ឆ្នាំមែនទេ ? ជាជនជាតិអាមេរិក ? នោះអ្នកមានសិទ្ធិក្នុងការបោះឆ្នោតហើយ ។ ព្យាយាមទទួលយកព័តិមាន ហើយរៀបចំខ្លួន ធ្វើដូច្នេះដើម្បីឱ្យអ្នកអាចបោះឆ្នោតនៅ **ថ្ងៃបោះឆ្នោត** បាន ។ ខាងក្រោមនេះជា **វិធីងាយៗប្រាំបួន** ដើម្បីធានាថាសន្លឹកឆ្នោតរបស់អ្នកត្រូវបានរាប់បញ្ចូល ។

## ១. ចុះឈ្មោះដើម្បីបោះឆ្នោត

ពេលកំណត់ចុះឈ្មោះអ្នកបោះឆ្នោតភាគច្រើន គឺក្នុងខែតុលា ។ ស្វែងរកពេលកំណត់ក្នុងរដ្ឋរបស់អ្នក ។

## ២. បញ្ជាក់ថាអ្នកត្រូវបានចុះឈ្មោះបោះឆ្នោតនៅអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក

ទូរសព្ទទៅការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នក ដើម្បីឱ្យប្រាកដថាគ្មានបញ្ហាជាមួយការចុះឈ្មោះរបស់អ្នក ជាពិសេស ប្រសិនថ្មីៗនេះអ្នកបានប្តូរអាសយដ្ឋាន ប្តូរឈ្មោះរបស់អ្នក ឬមិនបានបោះឆ្នោតនៅក្នុងការបោះឆ្នោតថ្មីៗនេះ ។

## ៣. បោះឆ្នោតឱ្យបានមុនគេ

ដើម្បីឱ្យកាន់តែមានភាពងាយស្រួល រដ្ឋមួយចំនួនអនុញ្ញាតិឱ្យបោះឆ្នោតមុនដោយផ្ទាល់ និង/ឬដោយសំបុត្រ។ ចូរស្វែងរកថាតើអ្នកអាចបោះឆ្នោតមុន ឬអត់ ។ កត្តានេះក៏នឹងអនុញ្ញាតិឱ្យអ្នកធ្វើការស្ម័គ្រចិត្តនៅ **ថ្ងៃបោះឆ្នោត** បានដែរ ។

## ៤. ស្វែងរកកន្លែងបោះឆ្នោតរបស់អ្នក

ទូរសព្ទទៅការិយាល័យបោះឆ្នោតក្នុងតំបន់ដើម្បីស្វែងរកកន្លែងបោះឆ្នោតរបស់អ្នក ហើយសួររករាល់នីតិវិធី និងតម្រូវការថ្មីៗសម្រាប់ការបោះឆ្នោត ។ ទីកន្លែងអាចផ្លាស់ប្តូរ ហើយឆ្នោតដែលបោះខុសកន្លែងអាចមិនត្រូវរាប់បញ្ចូល ។

## ៥. យកអត្តសញ្ញាណដែលសមស្រប

ស្វែងយល់ថាតើអត្តសញ្ញាណអ្វីដែលត្រូវការដើម្បីបោះឆ្នោតក្នុងរដ្ឋរបស់អ្នក ។ យកអត្តសញ្ញាណទៅទៅកន្លែងបោះឆ្នោតក្នុងករណីត្រូវការវា ជាពិសេសនោះគឺ អត្តសញ្ញាណដែលចេញដោយរដ្ឋាភិបាល ឬបណ្ណទារប្រាក់សម្រាប់ការប្រើប្រាក់

សេវា បណ្ណទារថ្លៃទូរសព្ទ ឬបណ្ណបើកប្រាក់ដែលមានឈ្មោះ និងអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក។ តម្រូវការអាចមានការខុសប្លែក ប្រសិនវាជាការបោះឆ្នោតលើកដំបូងរបស់អ្នក។

## ៦. នាំមិត្តភក្តិ ឬសមាជិកគ្រួសារម្នាក់របស់អ្នក

យោងតាមច្បាប់សហព័ន្ធ អ្នកអាចនាំមិត្តភក្តិម្នាក់ទៅកន្លែងធុងឆ្នោតដើម្បីជួយអ្នកក្នុងការបកប្រែ។

## ៧. សុំសន្លឹកឆ្នោតថ្មីមួយសន្លឹកប្រសិនអ្នកមានកំហុស

យោងតាមច្បាប់សហព័ន្ធ អ្នកមានសិទ្ធិទទួលបានសន្លឹកឆ្នោតថ្មីមួយសន្លឹក ប្រសិនអ្នកមានកំហុស។

## ៨. កុំចាកចេញដោយមិនបានបោះឆ្នោត

នៅថ្ងៃបោះឆ្នោត ប្រសិនអ្នកមកយឺត ហើយឋិតនៅក្នុងជួរនៅពេលកន្លែងបោះឆ្នោតបិទ ត្រូវនៅក្នុងជួរនោះ ដោយសារអ្នកមានសិទ្ធិបោះឆ្នោត។

## ៩. អ្វីដែលត្រូវធ្វើប្រសិនអ្នកទទួលបានសន្លឹកឆ្នោតបណ្តោះអាសន្ន

បុគ្គលិកកន្លែងបោះឆ្នោតអាចប្រាប់អ្នកថាមានបញ្ហាមួយជាមួយការចុះឈ្មោះរបស់អ្នក (ឧទាហរណ៍ ដូចជា ឈ្មោះរបស់អ្នកមិនឋិតក្នុងបញ្ជីអ្នកបោះឆ្នោត) ហើយផ្តល់ឱ្យអ្នកនូវសន្លឹកឆ្នោតបណ្តោះអាសន្នមួយសន្លឹក ។ សួរថាតើអ្នកឋិតក្នុងបរិវេណត្រឹមត្រូវ ឬអត់ ។ ប្រសិនគ្មានជម្រើសផ្សេងទៀតទេ ត្រូវគូសលើសន្លឹកឆ្នោតបណ្តោះអាសន្ននោះ។

ចំណាយដោយ អូបាម៉ា ដើម្បីអាមេរិក ។